# ប្រវត្តិអ្នកញៀនស្រាអនាមិកម្នាក់

ភាពធំដឹងក្តីក្នុងជីវិតជាកសិករម្នាក់ដែលរស់នៅជំបន់ភ្នំនិងវាលស្រែក្នុងខេត្តព្រះសីហានុជាស្រុកកំណើតទី២របស់ខ្ញុំ។
តាមពិតខ្ញុំជាក្មេងម្នាក់ដែលកើតនៅជុំរំមួយក្នុងប្រទេសថៃដែលនៅជិតព្រំប្រទល់កម្ពុជាយើង។ នៅទីនោះខ្ញុំមិនដែលស្គាល់ថាស្រែបែមុខទៅណាទេ ទាំងម្ហូបអាហារ ទាំងទឹកមានរបបគេចែកអោយ។ នៅជំរុំឪពុកម្តាយខ្ញុំជាអ្នករកស៊ីជួញស្ករ លក់ទឹកកកឈូសនិង ស្រារដបដៃរ( នៅជំរុំក្នុងការលក់ស្រាគឺលក់ដោយលួចលាក់មិនបើកចំហរទេ )។ខ្ញុំចាំបានថាៈ មានម្តងនោះ ខ្ញុំប្រហែលជាអាយុបាន១០ឆ្នាំឪពុកបានប្រើខ្ញុំអោយយកស្រារដាក់ក្នុងអាវរួចយកទៅលក់អោយអ្នកជាប់ឃុំឃាំងក្នុងជុំរុំ ដែលពួកគេភាគច្រើនគឺ ជាអ្នកចេញចូលខុសច្បាប់។ ពីក្មេងខ្ញុំមិនដឹងថាអ្វីទៅជាស្រារទេ។ ឪពុកម្តាយខ្ញុំពួកគាត់រកស៊ីលក់ស្រារមែន ប៉ុន្តែពួកគាត់មិនចេះផឹកស្រារនិងមិនចូលចិត្តអ្នកប្រមឹកដែរ។ រហូតដល់ឆ្នាំ១៩៩៣ គេបញ្ជូនខ្មែរទាំងអស់មកកម្ពុជាវិញ ហេតុដូច្នេះហើយឪពុកក៏សំរេចចិត្តមករស់នៅស្រុកកំណើតរបស់គាត់វិញនៅភូមិមួយក្នុងខេត្តព្រះសីហានុរហូតមកដល់សព្វថ្ងៃនេះ។

ពេលមកដល់ដំបូងខ្ញុំស្បាយណាស់បានឃើញវាលស្រែ សត្វគោ និងមានសេរីភាពមែនទែន។ អ្នកភូមិទាំងអស់មានអ្នកខ្លះស្វាគមន៍ និងអ្នកខ្លះគេមិនសូវស្វាគមន៍គ្រួសារខ្ញុំដែរ។ ជាធម្មតាអ្នកភូមិមានទំលាប់ក្រោយសំរាកពីការងា ឬពេលទំនេរ គេតែងតែអង្គុយជុំគ្នាហូបស្រារជជែកគ្នាលែង។ ពេលឪពុកប្រាប់គេថាអត់ចេះផឹកនិងអត់ចូលរួមផឹកជាមួយពួកគេមិនសូវស្វាគមន៍ពួកយើងប៉ុន្មានទេ។ មានថ្ងៃមួយឪពុកបានចូលរួមហូប ស្រាជាមួយគេម្តង ដោយសារតែមានកម្មវិធីបុណ្យនៅផ្ទះយាយនិងមិនអាចប្រកែកបាន (ខ្ញុំក៏នៅទីនោះដែរ)។ មិនយូប៉ុន្មានស្រាប់តែលឺសំលេងដបបែកលឺសូរ “ផាំង”! ធ្វើអោយផ្អើលមនុស្សពេញទាំងរោងបុណ្យ សំលេងដបបែកនោះគឺបណ្តាលមកពីឪពុកខ្ញុំបានគប់ដបស្រារទៅនឹងជើងតាងសសរផ្ទះ។ ឪពុកគប់ដបគឺនៅក្នុងវង់ហូបស្រារនោះ ពីព្រោះតែមានអ្នកឌឺដងអោយគាត់ ហើយគាត់គិតថាគេមើលងាយគាត់ ហេតុដូច្នេះហើយបានជាគាត់គប់ដប។ អ្នកនៅក្នុងវង់ហូបស្រានិយាយថាៈ គាត់ហូបស្រវឹងហើយបានជាគាត់គប់ដបអ៊ីចឹងនោះ។ តាមពិតឪពុកអត់ស្រវឹងទេ មកពីគាត់ខឹងអ្នកឌឺអោយគាត់។ បន្ទាប់ពីនោះ ឪពុកក៏ដើរចេញហើយឡើងទៅសំរាកនៅលើផ្ទះវិញ។ កាលនោះខ្ញុំអាយុបាន១១ឆ្នាំ ខ្ញុំមានអារម្មណ៍ខ្មាស់គេបន្តិច និងស្លុតបន្តិចដែរពេលមានរឿងអ៊ីចឹងកើតឡើង។ និយាយតាមត្រង់ទៅនៅភូមិដែលខ្ញុំរស់នៅនេះ អ្នកភូមិភាគច្រើនចូលចិត្តផឹកទាំងប្រុសទាំងស្រី និងលេងល្បែងស៊ីសង។

ក្នុងអំឡុងពេលពីឆ្នាំ១៩៩៦ដល់ឆ្នាំ២០០០ ខ្ញុំនៅជាក្មេងទំទង់នៅឡើយ។ពេលនោះ ខ្ញុំមានរឿងជាច្រើនដែលបានឆ្លងកាត់បទពិសោធន៍ខ្លះជាមួយនឹងស្រា និងមានទំនោរមិន ចូលចិត្តអ្នកប្រមឹកផងដែរ។ តាមទម្លាប់អ្នកភូមិកាលសម័យនោះការផឹកស៊ីមិនសូវ ជាទូលំទូលាយខ្លាំងដូចសម័យបច្ចុប្បន្នទេ។ គេនិយមការស៊ីផឹកដែរនៅពេលមានកម្មវិធី។

និយាយដល់កម្មវិធីនៅភូមិ បានធ្វើឲ្យខ្ញុំនឹកឃើញ កាលខ្ញុំនៅអាយុ១៦ ឆ្នាំគេមាន ពិធីរៀបការអ្នកជិតខាង ហើយខ្ញុំបានជួយធ្វើជាអ្នករត់តុក្នុងកម្មពិធី នោះ។ក្នុងពិធីនោះ មានភ្ញៀជាច្រើនចូលរួម ដោយគេភាគច្រើននិយមហូបស្រាជាធម្មតា មានអ្នកខ្លះផឹកតិច មានអ្នកខ្លះផឹកច្រើនតាមសមត្ថភាពរបស់ពួកគេ ហើយគេតែងតែឲ្យស្រាទៅអ្នករត់តុផឹក ម្តងមួយកែវជារឿយៗដែរ។ កាលនោះមានភ្ញៀវម្នាក់ជាអ្នកជិតខាងខ្ញុំ គេឲ្យស្រាមកខ្ញុំផឹក តែខ្ញុំប្រាប់គេថា "ខ្ញុំអត់ចេះផឹកទេ" គេនិយាយថា "បើមិនរៀនមិចនឹងចេះ! ដាក់បន្តិចវាមិនអីទេ"។ ដោយការគោរព និងបង្ហាញពីការគួសម ខ្ញុំក៏ព្រមញ៉ាំប្រហែល១ភាគ១០នៃកែវ ហើយកាលនោះគេនិយមផឹកស្រាសរឬស្រាកឹឡាកាសជាប្រភេទស្រាជប។ នេះជាលើក ដំបូងហើយដែលខ្ញុំផឹកស្រា។ តាមពិតស្រាមានរស់ជាតិខ្លាំង ឈ្ងួល ពិបាកលេប ល្វីង ខ្លិនមិនគួជាទីរាប់អានទេ។ ក្រោយពីផឹកហើយខ្ញុំស្រវឹង ទន់ដៃទន់ជើង បើកភ្នែកអត់រួច មានរម្មណ៍ថាធ្ងន់ក្បាលមែនទែន ធ្វើឲ្យខ្ញុំធ្វើអ្វីលែងកើតមានតែដេករហូតដល់ភ្លឺ ខកជើង មិនបានរាំទៀតផងនៅល្ងាចយប់នោះ និង"មានអារម្មណ៍ថាស្តាយរាំមែនទែន"។ តាំងពី ពេលនោះមកធ្វើឲ្យខ្ញុំមិនចង់ស្គាល់ទេស្រារ។

នៅភូមិខ្ញុំនៅសម័យនោះមានអ្នកផឹកភាគច្រើនជាអ្នកមានប្រពន្ធចាស់ៗនិង មនុស្ស ពេញវ័យ គេនិយមផឹកស្រាសរ ពីព្រោះស្រាបៀរថ្លៃ គ្រប់កម្មវិធី មិនថា រៀបការ ជប់លាង បុណ្យតូច បុណ្យធំ ឬបុណ្យខ្មោចទេត្រូវតែមានស្រាកំដរជានិច្ច។

លើកទីពីរខ្ញុំផឹកពេលមានពិធីឡើងផ្ទះរបស់ខ្ញុំ កាលនោះខ្ញុំអាយុ១៧ឆ្នាំ ក្នុងចំណោម មិត្តភក្តិនៅភូមិខ្ញុំជាក្មេងម្នាក់ ដែលមិនចេះផឹកស្រាទេ។ រាល់ពេលពួកគេផឹកស្រាមិនថា លាយទឹកដូងឬកូការទេខ្ញុំមិនផឹក តែដោយសារមិត្តភក្តិ និងចាស់ៗគាត់មក ជួយធ្វើផ្ទះ ហើយ ណាមួយគ្រួសារខ្ញុំគ្មានអ្នកចេះផឹកស្រាទៀត ដោយអត់មានអ្នកណាអង្គុយកំដរពួក គេ ខ្ញុំក៏អង្គុយកំដរនិយាយគ្នាលេង និងកំដរគេផឹកស្រាសរដែរ។ គេផឹកវិលជុំ ដោយម្នាក់ ម្តងកន្លះគូទកូនកែវដោយមានម្នាក់ជាអ្នកបោះមេ។ ពេលនោះខ្ញុំឃើញមិត្តភក្តខ្ញុំគាត់ផឹក ច្រើនហើយតែគាត់អត់ទាន់ស្រវឹងសោះ ខ្ញុំសសើរគាត់មែនទែន!។ ធម្មតាពួកគាត់ ផឹកក្នុង ផ្ទត់គំនិតចង់ផ្ចាញ់គ្នាដែរ ព្រោះមានអ្នកខ្លះអួតក្នុងការផឹក។ ខ្ញុំជាប្រុសម្នាក់ដែរខ្ញុំក៏មិន ចង់ចាញ់ដែរ ខ្ញុំក៏សួរគាត់ថា "ផឹកយ៉ាងម៉េចបានអត់ស្រវឹង?" គាត់ប្រាប់ថា "ពេលផឹកស្រា

ហើយផឹកទឹកបន្តិចទៅ” ខ្ញុំរៀនធ្វើតាម តែនៅតែស្រវឹង។ តាមពិតអ្នកផឹកខ្លះមាន ល្បិចក្នុងការផឹកដូចជា ផឹកហើយស្ដោះទឹកមាត់ដោយស្រាតាម(ស្ដោះស្រាចោល) មានអ្នកខ្លះយកក្រមាជូតម៉ាត់ដោយស្រាតាមដែរ(ស្ដោះស្រាចូលក្រមាខ្លះៗ)។ ប៉ុន្តែអ្នកផឹកដែលដុះមេហើយបើមិនសរសើមិនបានទេផឹកមិនក្លែមក៏បាន ផឹកដូចផឹកទឹក ផឹកមិនចេះក្អួត ផឹកមួយកន្លែងហើយទៅរកកន្លែងផឹកមួយទៀតដើរត្រេតត្រតមិនត្រង់ផ្លូវហើយនូវតែផឹកទៀត រហូតឆ្កែលិតម៉ាត់ និងដេកកន្លែងណាក៏បាន។ ឲ្យតែខ្ញុំជួបអ្នកផឹកដុះមេបែបនេះខ្ញុំតែងតែមិនចង់រាប់រកប៉ុន្មានទេ។និយាយពីនៅផ្ទះខ្ញុំ កាលនោះ ម្ដាយខ្ញុំបើកតូប លក់ឥវ៉ាន់ចាប់ហ្បួយនិងស្រាដែរ។ ពេលខ្ញុំឃើអ្នកផឹកដុះមេផឹកស្រាម្ដងៗ ពួកគេផឹកដូចផឹកទឹក ហើយញញ្ជក់ម៉ាត់ “ឆ្ងាញ់ណាស់” ធ្វើឲ្យខ្ញុំព្រឺសម្បុរខ្វាក ពេលឃើញពួកគេផឹក ក្នុងចិត្តខ្ញុំគិតថា៖“មិនឆ្ងាញ់ទេ”។ ពេលខ្លះមានអ្នកមកផឹកជាក្រុមបីទៅបួននាក់ ផឹកបណ្ដើរអួតបណ្ដើរ ពេលខ្លះផឹកហើយភ្នាល់គ្នាស៊ីកែវក៏មាន ពេលខ្លះក៏មានរឿងទាស់ទែងវាយគ្នាក៏មាន។ តាមព្រឹត្តិករណ៍ទាំងអស់នេះធ្វើឲ្យខ្ញុំមានប្រតិកម្មមិនចូលចិត្ត”អ្នកផឹកស្រា”ទាល់តែសោះ។

ខ្ញុំក៏ជាក្មេងម្នាក់ដែលមានកំលាំងខ្លាំង ឧស្សាហ៍ធ្វើការចូលចិត្តជួយអ្នកផ្សេង ចេះអត់ធ្មត់ក្នុងការងារ មិនសូវចេះនិយាយច្រើន ចូលចិត្តដើរលេង ញ៉ាំបង្អែម និងផ្លែឈើជាមួយមិត្តភក្តិក្នុងភូមិ អ្នកភូមិផងរបងជាមួយគោរពស្រឡាញ់រាប់អាន ខ្ញុំគ្រប់ៗគ្នា(នៅជំនាន់នោះមិនសូវមានក្មេងជំទង់ចេះផឹកស្រាប៉ុន្មានទេនៅភូមិខ្ញុំ)។

ក្រោយពីប្រឡងធ្លាក់ថ្នាក់ទី៩ ហើយក៏ឈប់រៀនបានពីឆ្នាំ ឪពុកបានសុំខ្ញុំអោយបួសរៀនបន្តនៅភ្នំពេញ ពីព្រោះផ្នត់គំនិតឪពុកខ្ញុំ”កូនប្រុសត្រូវតែរៀនអោយច្រើន ជាអ្នកស្នងត្រកូល”។ អញ្ចឹងខ្ញុំក៏បានបួសឡើងមករៀននៅឯភ្នំពេញនាឆ្នាំ២០០០។ ក្នុងភេទជាលោកសង្ឃធ្វើអោយខ្ញុំកាន់តែរឹងមាំខាងផ្លូវចិត្ត សេចក្ដីស្រឡាញ់ និងភាពអត់ធ្មត់ និងជាពិសេសខ្ញុំមានឱកាសបានទៅរៀននៅប្រទេសឥណ្ឌូនេស៊ីជិត៣ឆ្នាំទៀត។ក្រោយមកខ្ញុំក៏បានរៀនចប់វិទ្យាល័យខាងសាលាព្រះសង្ឃនៅភ្នំពេញ និងរៀនបរិញ្ញាប័ត្ររងផ្នែក អាយធីនៅសកលវិទ្យាល័យអាស៊ីអឺរ៉ុបប៉ុន្តែដោយមានផលវិបាកក្នុងការសិក្សា ខ្ញុំក៏បានសំរេចចិត្តសឹកលាចាកសិក្ខាបទនៅឆ្នាំ២០០៧។

*តាមពិតព្រះពុទ្ធបានមានពុទ្ធដីកាថា៖”សុំកុំសេពនូវគ្រឿងស្រវឹងទាំងឡាយ” នេះជាពាក្យប្រៀនប្រដៅមួយនៅក្នុងសីលប្រាំ និងមានន័យជ្រាលជ្រៅណាស់ក្នុងជីវិតរស់នៅដែលពេញដោយសន្តិភាព។”*

ក្រោយពីសឹកហើយបាន១ខែខ្ញុំបានទៅធ្វើការដ្ឋានសាងសង់ផ្លូវជាមួយបងថ្លៃខ្ញុំនៅតំបន់ភ្នំមួយនៅពេជ្រនិល ប្រហែល២ខែ។ ដោយបងថ្លៃឃើញខ្ញុំចូលចិត្ត អានសៀវភៅពេលទំនេរ អញ្ចឹងគាត់បានលើកទឹកចិត្តខ្ញុំអោយទៅរៀនបន្តនៅឯភ្នំពេញវិញ។

ការវិលត្រឡប់មកវិញម្តងនេះ ជីវិតនិងការរស់នៅរបស់ខ្ញុំចាប់ផ្តើម ផ្លាស់ប្តូរបន្តិចម្តងៗ ចាប់ផ្តើមពីខ្ញុំចេះផឹកស្រាពីមួយកំប៉ុងស្រវឹងរហូតដល់៣កំប៉ុងបានស្រវឹង និងចេះផឹកច្រើនឡើងៗ។ តាំងពីដើមរហូតមកដល់ឥឡូវនេះ គេនិយមយកស្រាមកធ្វើ ជាមិត្តនិងជាមេត្រីមុខក្នុងការរាប់អានគ្នា "មានស្រា មានមិត្ត"។ ដោយសារតែខ្ញុំចង់មានមិត្តភ័ក្តដើរលេងសប្បាយ ចង់ស្គាល់សង្គមថ្មី (ដើរអោយទាន់សង្គម) ចង់ចូលរួមគ្រប់ សកម្មភាពដែលមិត្តភក្តិធ្វើ និងមានអំនួតតាមបែបជាមនុស្សប្រុសនិងមិនចង់អោយ គេថាគីឡូ ស្រាលអន់ៗ ហេតុដូច្នេះហើយ ខ្ញុំក៏ខំរៀនផឹក និងចាប់ផ្តើមមានទំលាប់ចូលចិត្តផឹកស្រា។ ដោយខ្លួនឯងខ្ញុំទាំងនៅមានទស្សនៈមួយថា"ស្រាល្វីងនិងមានក្លិនខ្លាំងប៉ុន្តែហេតុអ្វីមនុស្សចូលចិត្តផឹកម្លេះ"។ ក្នុងឆ្នាំដដែលនោះដែរខ្ញុំក៏មានសង្សារម្នាក់ តាមពិតសង្សារខ្ញុំមិនចូលចិត្តអ្នកចេះផឹកស្រានោះទេ គាត់តែងតែខឹងខ្ញុំពេលខ្ញុំយកលេសទៅផឹកស្រាជាមួយមិត្តភក្តិ ដោយមិនសូវចំណាយពេលជាមួយគាត់អោយច្រើន។ មានពេលខ្លះខ្ញុំបានខឹងនឹងសង្សា "ហេតុអ្វីគាត់មិនចង់ឲ្យខ្ញុំមានសេរីភាព និងមានមិត្តភក្តិ"។តាមរឿងនេះ កាន់តែធ្វើអោយខ្ញុំ ផឹកជាងមុន ព្រមទាំងផឹកឌឺដាក់សង្សាដោយមិនដឹងខ្លួនទៀតផង ព្រោះតែខ្ញុំនៅមានផ្នត់ គំនិតមួយថា៖ "ស្រីៗមិនយល់ពីមនុស្សប្រុស" និង"ខ្ញុំមិនត្រូវតាមស្រីៗរហូតទេ កុំអោយស្រីៗគ្រប់គ្រងយើងបាន" ខ្ញុំបែរទៅផឹកអោយច្រើនធ្វើអោយគាត់អាណិតខ្ញុំ និងអោយគាត់ព្រមទទួលយកកាផឹករបស់ខ្ញុំ និងចង់អោយគាត់ចូលរួមផឹក ដែរ(***ការទាំងអស់នេះសុទ្ធតែជាលេសក្នុងការផឹក និងគតិខុសឆ្គងមួយដែលខ្ញុំបានភ្ជាក់ខ្លួន ដឹងក្រោយពេលបែក គ្នាជាមួយសង្សា និងក្រោយពេលខ្ញុំបានដើរជាមួយ អេអេធ្វើលំហាត់ក្នុងជំហានទីបួន***)។នៅពេលនោះខ្ញុំមិនដែលគិតថា ខ្ញុំជាអ្នកញៀនស្រាទេ។ ពេលខ្លះខ្ញុំធ្លាប់គិតថា ស្រាអាចបំផ្លាញសុខភាព ស្មារតី អស់លុយ និងពេលខ្លះអស់តំលៃជាមនុស្ស ដូចគេថា"ស្រាថ្លៃ ប៉ុន្តែមនុស្សថោក"។ ខ្ញុំនឹកឃើញកាលពីឆ្នាំ២០០៨ ខ្ញុំចូលចិត្តដើរផឹកពីកន្លែងមួយទៅកន្លែង មួយជាមួយមិត្តភក្តិ ពេលខ្លះចេញពីបៀរហ្គាឌិនវិញត្រូវគេដេញវាយដួលម៉ូតូក៏មាន ពេលខ្លះមិត្តភក្តិពេលផឹកស្រវឹងចូលចិត្តបោកកែវក៏មាន និងមានថ្ងៃមួយនោះមិត្តភក្តិ ស្រវឹងចង្អុលមុខប៉េអឹម ហើយត្រូវប៉េអឹមភ្លុងកាំភ្លើង វាយហើមមុខហើមមាត់ក៏មាន។ ពេលខ្លះផឹកស្រាស្រវឹងបាត់សតិ ចូលចិត្តទៅលេងស្រី និងប្រើកាយវិការមិនសមរម្យ ទៅលើស្រី និងប្រើពាក្យសំដីមិនគួសមទាល់តែសោះ(ពេលចូលខេធីវី) ហើយនិងមានមិត្តភក្តខ្ញុំម្នាក់បានជិះម៉ូតូ ចូលឡាន ហើយត្រូវឡានកិនស្លាប់ផងដែរ។ ហេតុការណ៍ទាំង អស់នេះសុទ្ធតែបង្ហាញថាយើង

គ្មានអំណាចលើស្រាទេ ប៉ុន្តែអំណួត ចិត្តតប់ប្រមល់ កំហឹង ចង់បានការសរសើរ និងភាពឯកោរបស់ខ្ញុំមិនដែលឲ្យខ្ញុំគិតឃើញពីចំណុចមួយនេះទេ។ដោយមានរឿងច្រើនកើតឡើងប្លុករួមទាំងការបែកគ្នាជាមួយសង្សារ ខ្ញុំក៏សំរេចចិត្តឈប់ផឹកស្រាបានប្រហែល១ខែ។ ពេលនោះខ្ញុំគិតថា ខ្ញុំអត់អោយតំលៃទៅសង្សា និងយកពេលជាមួយគាត់ឲ្យបានច្រើន និងធ្វើអោយគាត់ពិបាកចិត្តលែងទុកចិត្តលើខ្ញុំ ខ្វះភាពកក់ក្តៅ អស់ជំនឿលើខ្ញុំ ដោយសារតែខ្ញុំបានអោយតំលៃទៅលើស្រា និងមិត្តភក្តិធំពេកដើម្បីផឹក។ ក្នុងរយៈពេលឈប់ផឹក ខ្ញុំមានរម្មណ៍ថាខ្លួនរបស់ឈឺសសៃសស្វង ឈឺឆ្អឹងឈឺឆ្អែង និងស្ពឹកៗមុខ ហើយដូចជាមនុស្សមិនសូវមានអារម្មណ៍នៅជាប់នឹងខ្លួនទេ។
ហើយមួយទៀតខ្ញុំមានអារម្មណ៍ថាខ្ញុំអាចគ្រប់គ្រងខ្លួនឯងបានក្នុងការផឹក “ខ្ញុំផឹកក៏បានអត់ផឹកក៏បាន ចង់ឈប់ពេលណាក៏បាន”។ បន្ទាប់មកខ្ញុំមានគំនិតថា៖យើងផឹកតិចតួច ១កំប៉ុង ២កំប៉ុងវាមិនអីទេ ដោយខ្ញុំចូលចិត្តចូលរួមជាមួយមិត្តភ័ក្តដើម្បីកំដរ ភាពឯកោររបស់ ខ្ញុំ“ខ្ញុំក៏ចាប់ផ្តើមផឹកឡើងវិញម្តងទៀត”។ នៅពេលផឹកម្តងទៀតមានអារម្មណ៍ថា ខ្ញុំដូចជាមនុស្សស្រេកទឹក ផឹកស្រាឆ្ងាញ់មែនទែន អត់ល្វីង អត់ឈ្ងួលដូចមុនទេ “ខ្ញុំមានអារម្មណ៍ដូចពេលដែលយើងអស់កំលាំង ពេលក្តៅខ្លាំង ហើយបានទឹកកកមួយកែវមកញ៉ាំអីចឹងត្រជាក់ចិត្តមែនទែន ត្រជាក់ស្រេបតែម្តង!”។

តាមពិតទៅខ្ញុំគឺជាគ្រូបង្រៀនភាសារខ្មែរម្នាក់បានចាប់ផ្តើមបង្រៀននៅអង្គការមួយនៅចុងឆ្នាំ២០០៧ ហើយក៏ជាពេលដែលខ្ញុំចាប់ផ្តើមចេះផឹកដែរ បន្ទាប់ពីមានបញ្ហាច្រើនក៏ឈប់ផឹកបានមួយខែក្នុងឆ្នាំ២០០៨ ហើយក៏បន្តផឹកឡើងវិញ។ ហើយការបន្តផឹក របស់ខ្ញុំកាន់តែជំនាញជាងមុន។ រាល់ល្ងាច ពេលចេញពីធ្វើការ ខ្ញុំតែងតែបបួលមិត្តភ័ក្ត ឬមិត្តភ័ក្តបបួលខ្ញុំម្នាក់ម្តងដើម្បីទៅផឹក ឬពេលខ្លះ ខ្ញុំអផ្សុក ធុញម្ជូម៉ៅឬខឹងពីកន្លែងធ្វើការ ពីជីវិតខ្លួនឯង ពីសង្គមនិងបរិស្ថានជុំវិញ ឬពេលមានម្ហូបឆ្ងាញ់ខ្ញុំតែងតែផឹកជាប្រចាំ។ ជួនកាលអត់មានមិត្តភក្តិ ខ្ញុំក៏ទៅផឹកម្នាក់ឯង ក្លែមសាច់ឆ្អែស្រាថ្នាំនៅពេលអត់លុយ ពេលមានលុយរកមើលស្រា រឺស្រាប៉ៀរណាប្លែកៗដើម្បីផឹក (ពេលហ្នឹងមានអារម្មណ៍ថា ពេលឃើញស្រា នឹកពីស្រា ឬលឺពីស្រា គួឲ្យស្រក់ទឹកមាត់)។ ខ្ញុំផឹកតាំងពីកន្លះលីត្រស្រវឹងរហូតដល់១លីត្រ២លីត្រអត់ទាន់ផ្កាប់មុខទេឥឡូវ។ ខ្ញុំបានបន្តផឹករាល់ថ្ងៃ មួយថ្ងៃពី៤ទៅ៥កំប៉ុង ឬ២ទៅ៣ដប និងពេលជួបមិត្តភក្តិពីរបីនាក់ផឹក២ទៅបីកេសជាប្រចាំ និងផឹកពីព្រឹក រហូតដល់យប់ ផឹកពីយប់រហូតដល់ព្រឹកផឹកទៀតក៏មាន។រាល់ការទៅលេងផ្ទះម្តងៗខ្ញុំតែងតែជួយធ្វើការឪពុកម្តាយនៅផ្ទះពីព្រោះខ្ញុំជាកូនឧស្សាហ៍ម្នាក់ដែរ រាល់ពេលធ្វើការខ្ញុំផឹកបណ្តើរធ្វើការបណ្តើរ មិនថាធ្វើការផ្ចាល់ដី ទៅស្រែ កាប់ឈើ ឬឡើងដំបូល ផ្ទះទេ គឺផឹករហូតព្រោះអីនៅផ្ទះ ម្តាយខ្ញុំលក់ស្រាថ្នាំដែរ។ ឪពុកខ្ញុំគាត់សង្កេតមើលការផឹក របស់ខ្ញុំ

ហើយគាត់និយាយថា៖ “*អាអូន ឯងកាត់ទៅអ្នកណាគេបានជាផឹក រហូតនិងអត់ស្រវឹងអញ្ចឹង! ពូជអញដូចមិនមានទេ។*”ពេលលឺគាត់និយាយអ៊ីចឹង ខ្ញុំគ្រាន់តែញញឹមហឹមៗ ហើយក៏បន្តធ្វើការទៀត។

រាល់ពេលចូលឆ្នាំខ្មែរជាធម្មតាខ្ញុំទៅលេងផ្ទះ និងមានមិត្តភក្តិមកជួបជុំគ្នា ពីព្រោះមួយឆ្នាំម្តងបានជួបគ្នា ខ្ញុំនិងមិត្តភក្តិបបួលគ្នាអង្គុយផឹកពីផ្ទះមួយទៅផ្ទះមួយ ទៀតរហូតដល់យប់ទៅរាំធុងបាស់ នៅកន្លែងរាំគេមានស្រាសរស្វាគមន៍ជាប្រចាំ ពួកយើងក៏ផឹកផងរាំផងសប្បាយណាស់។ នៅយប់មួយហ្នឹង ប្រហែលជាម៉ោង៩យប់មាន ប្អូនប្រុសម្នាក់ជា អ្នកភូមិដូចគ្នាដែរ គាត់ស្រវឹងដាបហើយ គាត់ក៏មកចូលរាំដែរ។ ពេលបងប្អូនជីដូនមួយគាត់មកនិយាយប្រាប់អោយគាត់ទៅអង្គុយ ឬទៅគេងទៅ ពីព្រោះមើលទៅគាត់ស្រវឹងដាបហើយនិងរាំក្រូវគេឯងពេញវង់។ គាត់គ្រាន់តែលឺបងប្អូនប្រាប់អ៊ីចឹង គាត់បែជាខឹង អន់ចិត្តនិងរករឿងវាយគេឯងពេញវង់។

បងជីដូនមួយគាត់ទ្រាំមិនបានក៏មានការវាយគ្នាពេញវង់ទៅ(តាមពិតពួកយើងសុទ្ធតែផឹកស្រវឹកដូចគ្នាហើយតែមិនទាន់ដាបដូចគាត់នៅឡើយ)។ ខ្ញុំក៏នៅក្នុងហេតុការណ៍នោះដែរ ប៉ុន្តែខ្ញុំនិងមិត្តភក្តិបានត្រឹមតែឈរមើលប៉ុណ្ណោះ។ ប្រហែលតែមួយនាទីខ្ញុំឃើញឪពុកខ្ញុំមករកខ្ញុំដែរ ពីព្រោះកន្លែងរាំនៅជិតផ្ទះ។ នៅពេលឃើញឪពុកមក ពេលនោះខ្ញុំ ស្រាប់តែមានអារម្មណ៍ខឹងមួម៉ៅនឹងគាត់។ក្នុងចិត្តខ្ញុំមិនសប្បាយនិងមិនចូលចិត្តអោយគាត់មក កន្លែងមានរឿងដូចនេះទេ។ មិនបង្អង់យូខ្ញុំក៏ហៅគាត់ដើរទៅផ្ទះជាមួយគ្នាវិញ។ ពេលដល់ផ្ទះខ្ញុំបាននិយាយទៅគាត់ថា៖ “ប៉ា! ហេតុអ្វីបានជាប៉ាទៅ ពីព្រោះមនុស្សកំពុងវាយគ្នា” “មិនល្អទេ! បើមានរឿងចឹងទៀតកុំទៅធ្វើអីខ្លាចមានគ្រោះថ្នាក់”។ ឪពុកក៏ខឹងខ្ញុំវិញពេលលឺ ខ្ញុំនិយាយអ៊ីចឹងគាត់និយាយថា៖ អញទៅមើល ពីព្រោះខ្លាចកូនអញមានគ្រោះថ្នាក់ និងពេលមានរឿងកើតឡើងក្នុងភូមិ អញត្រូវតែដឹងលឺ។ ខ្ញុំបានតមាត់ជាមួយគាត់ទៅមក រហូតដល់គាត់និយាយថា៖ មកពីគាត់ជាមនុស្សល្ងង់មិនបានរៀនសូត្រដូចកូន អោយកូនមើលងាយអ៊ីចឹងឯង។

ខ្ញុំគ្រាន់តែលឺសំដីនោះភ្លាមក៏មិនមានសតិគិតពិចារណាច្រើនដូចមានអ្វីមកបាំងមុខអោយងងឹតសូន្យឆឹង។ ខ្ញុំគិតតែពីយំនិងលើកគុ កៅអីគ្រវែងគ្រវាត់ពេញក្រោមផ្ទះ យំននាលដីនិងរត់បោកក្បាល់នឹងសសរផ្ទះ ឃើញអ៊ីចឹងបងស្រី ប្អូនស្រី និងម្តាយមកចាប់ យកខ្ញុំឡើងទៅលើផ្ទះ។ ពួកគាត់បាននិយាយលួងខ្ញុំថា៖ ឈប់ស្តាប់ពាក្យគាត់ទៅ និងកុំនិយាយ តមាត់ជាមួយគាត់ដែរ។ បន្ទាប់មកខ្ញុំក៏ស្ងប់បន្តិចតែនៅបន្តយំរហូតដល់ដេកលក់ពីព្រោះ ស្រវឹងរាងធ្ងន់ក្បាលខ្លាំងដែរ។ លុះព្រឹកឡើងក្រោយស្វាងពីស្រា ខ្ញុំដូចជាមានវិប្បដិសារី ចំពោះរឿងនៅយប់មិញ។ ខ្ញុំបានអង្គុយនៅមុខជណ្តើរមានអារម្មណ៍ឈឺក្បាល និងយកដៃស្ទាប

ក្បាលមើល ក្បាលដូចជាពកធំ។ ខ្ញុំបានសួរខ្លួនឯងថា៖ ក្បាលខ្ញុំពកដោយសារអ្វីចេះ? ក្រោយពីខ្ញុំគិតបានតែមួយសន្ទុះ ខ្ញុំក៏នឹកឃើញថា៖ ខ្ញុំបានបោកក្បាលនិង សសរផ្ទះយប់មិញ។ ខ្ញុំអង្គុយអស់សំណើចខ្លួនឯង "ហេតុអ្វីបានជាខ្ញុំធ្វើរឿងឆ្កួតៗដូច្នេះ"។ ខ្ញុំក៏ទៅសុំទោសប៉ាក្រោយពីគាត់អោយបាយមាន់ទាគាត់ហើយ។ ខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាខ្ញុំ អាចធ្វើរឿងល្ងង់ដូចនេះបាន តាមពិតខ្ញុំជាបុរស់ខ្លាំងម្នាក់ មានឆន្ទះ មានស្មារតីខ្ពស់ ជាគំរូច្បងនៅក្នុងសង្គម និងជាគ្រូបង្រៀនម្នាក់ដែរ យ៉ាងដូចម្តេចបានជាធ្វើរឿងអីចឹងកើត។ ***(ចម្ងល់នេះនៅជាប់ក្នុងអារម្មណ៍រហូតដល់បានជួប អេអេទើបខ្ញុំយល់ច្បាស់)***

មានមិត្តភក្តិខ្លះមិនចូលចិត្តអ្នកផឹកស្រាទេតែខ្ញុំតែងតែផឹកខឹគេ "ខ្ញុំផឹកហើយ បានទៅជួបពួកគេដើម្បីធ្វើឲ្យគេឃើញថាខ្ញុំជាអ្នកផឹកមិនមែនជាមនុស្សថ្លៃថ្នូរទេ"។ មានពេលខ្លះទៀតជិតរាល់ចុងសប្តាហ៍ ខ្ញុំតែងតែផឹកជាមួយមិត្តភក្តិ អត់ទៅបង្រៀនទេ ជួនកាលពេលផឹកហើយទៅបង្រៀនក៏មាន រហូតដល់មិត្តភក្តិខ្ញុំម្នាក់គាត់ជាអ្នក គ្រប់គ្រង នៅសាលានោះបានខឹង និងអត់និយាយរកខ្ញុំទៀត។ ពេលនោះដូចជាមានអ្វីមួយមករំលឹកខ្ញុំថា សុំមើលពីខ្លួនឯង និងសួរខ្លួនឯងថា"***ហេតុអ្វីកាន់តែមានអត្តចរិកមិនល្អ ចូលចិត្តខឹ មិនគោរពតួនាទី មិនគោរពមិត្តភក្តិ មិនធ្វើជាគំរូល្អ មិនអោយតំលៃខ្លួនឯង និងអ្នកដទៃ យកលេសដើម្បីផឹក បើកប្រាក់ខែមកនៅសល់តែខែមិនតែប៉ុណ្ណោះជំពាក់ថ្លៃស្រាចិន និងខ្ចីលុយគេរាល់ខែ និង នឹកចាំពីសំដីរបស់ឪពុកខ្ញុំនិយាយមកខ្ញុំ ពីការសង្កេត របស់គាត់ ក្នុងការផឹករបស់ខ្ញុំដែរ ព្រមទាំងចម្ងល់ដែលដក់ជាប់អារម្មណ៍របស់ខ្ញុំ ក្នុងរឿងរ៉ាវជាមួយ ឪពុកផង***"។ ពេលនោះស្រាប់តែមុខរបស់ខ្ញុំប្រែប្រួល និងមានអារម្មណ៍អាណិតខ្លួនឯង រស់នៅពេញដោយក្តីអស់សង្ឃឹម ខ្មាសគេ មិនដឹងរកវិធីអ្វីដើម្បីដោះស្រាយ មានតែផឹកដើម្បីគេចពី រឿងទាំងអស់នោះនិងមិនត្រូវការគិតច្រើនផងដែរ ដឹងតែម្យ៉ាងគឺផឹក។

ដោយខ្ញុំចេះតែមានអារម្មណ៍ថា៖ ការចេះតែផឹកនេះមិនឲ្យខ្ញុំស្កប់ចិត្តទេ និងមានអារម្មណ៍ថាមិនមែនជាផ្លូវរបស់ខ្ញុំទេ មិនមែនជាខ្ញុំទៀតទេ លែងធ្វើឲ្យខ្ញុំមានអារម្មណ៍ថាសប្បាយ និងស្កប់ចិត្តក្នុងការផឹកដូចមុន***"តែហេតុអ្វីខ្ញុំនៅតែផឹក"***។

នៅដើមឆ្នាំ២០១៥ខ្ញុំបានស្បថនឹងព្រះ និងខាងមុខសង្ឃាថ្មីខ្ញុំថា៖ "ខ្ញុំឈប់ផឹកទៀតហើយ បើក្នុងស្ថានភាពបង្ខំមួយខ្ញុំផឹកតែមួយកំប៉ុងប៉ុណ្ណោះ"។ តាមការស្បថរបស់ខ្ញុំ មានប្រសិទ្ធិភាពបានតែ១ខែទេ។ ក្រោយមកខ្ញុំផឹកច្រើនដូចមុនវិញហើយ ខ្ញុំដឹងថា៖ ខ្ញុំបានកុហកនឹងព្រះនិងសង្ឃាដែរ ពេលខ្លះខ្ញុំកុហកសង្ឃាថាខ្ញុំផឹកតែមួយពីរកំប៉ុង តាមពិតច្រើនជាង១០កំប៉ុងក៏មាន។ នៅឆ្នាំនោះខ្ញុំចាប់ផ្តើមមានក្រុមបុរស ហើយជាធម្មតាខ្ញុំឧស្សាហ៍ជួបលោកគ្រូម្នាក់គាត់ជាជនជាតិអង់គ្លេសម្នាក់ឈ្មោះ **ហ្សូវ៉ាន់**ដែលតែងតែជួយក្រុមបុរស។

យើងតែងតែញ៉ាំកាហ្វេនិយាយគ្នាលេងរាល់អាទិត្យ ថ្ងៃមួយនោះខ្ញុំបាននិយាយពីការផឹកស្រារបស់ខ្ញុំប្រាប់គាត់ រួចគាត់ក៏បាននិយាយលើកទឹកចិត្តខ្ញុំ ហើយណែនាំខ្ញុំឲ្យជួបលោកគ្រូម្នាក់ទៀតជនជាតិអាមេរិចដែលគាត់នៅខ្មែរចាស់គ្រឹកចាស់គ្រែង ជាព្រឹទ្ធាចារ្យម្នាក់ ហើយគាត់ចេះនិយាយភាសាខ្មែររូហូដូចទឹកអឺចឹង គាត់ឈ្មោះលោកគ្រូ **ប្រាយឥន** (ឥឡូវគាត់ជាអ្នកចាស់ទុំរបស់ខ្ញុំដែរ)។ ថ្ងៃដំបូងដែលខ្ញុំជួបគាត់ ខ្ញុំមានអារម្មណ៍ភ័យបន្តិច ប៉ុន្តែតាំងចិត្តមកជួបគាត់ ព្រោះខ្ញុំចង់ឈប់ផឹកស្រា។ គាត់បានសួរ ខ្ញុំថា៖***"ប្អូនចង់ឈប់ផឹកស្រាទេ?"***។ ខ្ញុំឆ្លើយបាទ! ខ្ញុំចង់។ បន្ទាប់មកគាត់សួរពីរបីសំណួរល្អៗ ទៀតមកខ្ញុំ ហើយឲ្យកូនសៀវភៅ និងខិតប័ណ្ណពីអ្នកញៀណស្រារអនាមឹកមកខ្ញុំអាន។ គាត់និយាយថា៖ "ល្អដែលយើងចង់ឈប់ធ្វើជាទាសកររបស់ស្រា"។ ឃ្លានេះធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលមែនទែន ដែលពីមុនខ្ញុំមិនដែលគិតឃើញពីចំណុចនេះសោះ។ ហើយគាត់បានណែនាំខ្ញុំ ពីក្រុមអ្នកញៀនស្រាអនាមិក។ ហើយនៅក្នុងខិតប័ណ្ណមានរូបប្រុសម្នាក់នៅ ក្រោមដបស្រា និងជាប់ខ្នោះដៃទៀត តាមរូបនោះធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលមែន"ធ្វើឲ្យខ្ញុំអស់ សំណើចចំពោះខ្លួនឯងនៅក្នុងចិត្ត"។

*(លើកដំបូងដែលខ្ញុំទៅចូលរួមប្រជុំក្រុមអ្នកញៀនស្រាអានាមិកជាមួយគាត់)*

ក្នុងការប្រជុំមានអ្នកដឹកនាំម្នាក់ជួយដឹកនាំការប្រជុំ ដំបូងគេមានសូត្រសេចក្តីបួងសួងចប់ បន្ទាប់មកគេចាប់ផ្តើមណែនាំខ្លួនម្នាក់ម្តងដូចនេះ៖ "ខ្ញុំឈ្មោះគឹមលាង" "ខ្ញុំជាអ្នកញៀនស្រា"។ ការនិយាយាថា "ខ្ញុំជាអ្នកញៀនស្រា" ធ្វើអោយខ្ញុំស្ទាក់ស្ទើរក្នុងចិត្តបន្តិចរៀងខ្លាចបន្តិចមុននិយាយ ពីព្រោះពីមុនខ្ញុំមិនដែលគិតថាខ្ញុំជាអ្នកញៀនស្រាទេ។ ក្រោយមកខ្ញុំគិតថាឃ្លាមួយនេះជាជំហានមួយដំបូងនាំខ្ញុំ រំលឹកខ្ញុំ ធ្វើឲ្យខ្ញុំស្គាល់ខ្លួនឯង ថាខ្ញុំជាអ្នកណា និងឲ្យខ្ញុំចាប់ផ្តើមទំព័រថ្មីន័យជីវិត។

ខ្ញុំបន្តរៀនជាមួយគាត់ជំហានទាំង១២ ហើយគាត់ជាអ្នកឲ្យដំបូន្មានខ្ញុំ និងជួយខ្ញុំ ក្នុងការដើរជាមួយជំហានទាំង១២យ៉ាងម៉េច។ ជំហានទីបួនធ្វើឲ្យខ្ញុំកាន់តែស្គាល់ខ្លួនច្បាស់ការដែលខ្ញុំញៀណមិនមែនមកពីចង់បានមិត្តទេ។ ខ្ញុំញៀនដោយសារតែ ធ្វើបាបខ្លួនឯង (ដាក់ទណ្ឌកម្មខ្លួនឯង) ភាពឯការ ភាពភ័យខ្លាច ភាពអាម៉ាស ខ្វះសេចក្តីក្លាហាន គ្មានជំនឿលើខ្លួនឯង ចង់បានមុខមាត់និងការសរសើរ។ ដោយជំហាននេះតំរូវអោយយើងពិនិត្យមើលកំហុសនិងចរិកលក្ខណៈអាក្រក់របស់ខ្លួន ដើមហេតុពីអ្វី យើងទទួលបានអ្វី និងមានដំណោះស្រាយអ្វីក្នុងហេតុទាំងនោះ។ អ្វីដែលជួយឲ្យខ្ញុំមានស្ថេរភាពក្នុងការឈប់ផឹកគឺ "ជួយគេដូចជួយខ្លួនឯង" ខ្ញុំបានជួយធ្វើការខ្លះ កែសំរួលឯកសារអ្នកញៀនស្រាអនាមិក និងមានប្រជុំអ្នកញៀនស្រាអនាមិកខ្មែរដែរ។

ខ្ញុំបន្តមានស្ថេរភាពបានមួយឆ្នាំកន្លះហើយប៉ុន្តែរឿងដែលនឹកស្មានមិនដល់ខ្ញុំបានធ្លាក់ចុះម្តងទៀត។ ការធ្លាក់ចុះរបស់ខ្ញុំ ដោយសារខ្ញុំបានប្តូរការងារពីភ្នំពេញមកសៀមរាប។ នៅសៀមរាបអ្វីៗទាំងអស់ថ្មីសំរាប់ខ្ញុំ ទាំងកន្លែង ទាំងការងារ ទាំងមិត្តភក្ត ណាមួយខ្ញុំនៅឆ្ងាយពីអ្នកផ្តល់ឱវាទខ្ញុំ នៅឆ្ងាយពីក្រុមអ្នកញៀនស្រាអនាមិក និងមិត្តភក្តិខ្ញុំ។ រយៈពេលដែលខ្ញុំរស់នៅ និងធ្វើការនៅសៀមរាប ខ្ញុំមានអារម្មណ៍តប់ប្រមលច្រើន ការងារច្រើនពេកក្រោយពីចេញពីធ្វើការខ្ញុំតែងតែទៅទិញស្រាក្លូរ៉េមួយឬពីរដបទៅផឹកនៅផ្ទះដើម្បីកំដរអារម្មណ៍។ ពេលទិញគ្មានអ្វីមកហាមឃាត់អារម្មណ៍និងចិត្តរបស់ខ្ញុំក្នុងការទិញទេ។ ដោយយកលេសដាក់ផ្ទត់គំនិតមួយថា “ផឹកមួយដបពីដបមិនអីទេ”។ ខ្ញុំចេះតែទិញយកទៅផឹកមួយអាទិត្យ២ដង ឡើងទៅ៣ដង រហូតជិតរាល់ថ្ងៃ។ ដល់ថ្ងៃមួយដើមឆ្នាំ២០១៧ ខ្ញុំបានឡើងទៅលេងភ្នំពេញ ខ្ញុំស្នាក់នៅបន្ទប់ជាមួយប្អូនប្រុសម្នាក់ ជួនជាជិតដល់ថ្ងៃខួបរបស់គាត់ខ្ញុំក៏ទៅទិញម្ហូបក្លែមនិងស្រាក្លូរ៉េ៣ដបមក ញ៉ាំជាមួយគាត់ហើយ ក៏បបួលគ្នាទៅ ការ៉ាអូខេទៀតចេញពីការ៉ាអូខេ ខ្ញុំទៅទិញស្រាក្លូរ៉េ២ដបមកអង្គុយផឹកទៀត។ ពេលព្រឹកឡើងក្រោយក្រោកពីគេងខ្ញុំមានអារម្មណ៍ដូចជាខ្ញុំបានដាក់ខ្លួនឯងចូលទៅក្នុងគុកយ៉ាងងងឹតស្វូនសុង ដែកាន់របងគុកពេញដោយភាពអស់កំលាំង កំសត់ចិត្ត សំរក់ទឹកភ្នែក អាណិតខ្លួនឯង ឈឺចាប់ និងឈឺក្បាលមែនទែន។ នៅថ្ងៃនោះខ្ញុំអត់បានធ្វើអ្វីដូចដែលខ្ញុំ បានមានគំរោងហើយទេ។ ខ្ញុំសួរខ្លួនឯងនិងសួទៅព្រះសុំជួយខ្ញុំផង “ហេតុអ្វីបានជាខ្ញុំធ្លាក់ខ្លួន ទៅជាបែបនេះ”។ ខ្ញុំបានជិះម៉ូតូចេញពីផ្ទះរកទិញការហ្វេផឹក នៅតាមផ្លូវ ខ្ញុំចេះតែសួរខ្លួនឯងពេលនោះស្រាប់តែខ្ញុំនឹកចាំពាក្យមួយពីលោកគ្រូដែលជាអ្នកផ្តល់ឱវាទមកខ្ញុំថា
“ចំពោះអ្នកញៀនស្រាមិនអាចផឹកសូម្បីតែ១កែវឬកំប៉ុង បើគេផឹក គេនឹងបន្តផឹករហូតមិនអាចហាមឃាតខ្លួនឯងបានទេ”។ ខ្ញុំបានគិតនិងចាប់ផ្តើមយល់ ពីឃ្លាមួយនេះ ច្បាស់ បន្តិចម្តងៗ។ ចំពោះអ្នកញៀនស្រាសុទ្ធតែមានភាពញៀន(អារម្មណ៍ញៀនស្រា)នៅជាប់ក្នុងខ្លួនមិនមែនរសាយបាត់ទៅភ្លាមៗនោះទេគឺនៅរហូត វានឹងផុសឡើងនៅ ពេលណា យើងជួបស្ថានភាពដែលពិបាក ឬជំនឿខាងផ្លូវចិត្តយើងខ្សោយ។ តាំងពីថ្ងៃនោះមកខ្ញុំពិតជាត្រូវការក្រុមអ្នកញៀនស្រាអនាមិកណាស់។ តាមរយៈក្រុមអ្នកញៀនស្រាអនាមិក ជួយខ្ញុំឲ្យចេះស្មោះត្រង់ៗពីខ្លួនឯងរស់នៅដោយមិនលាក់ខ្លួន និងមិនឆ្ងាយពីអ្នកដ៏ទៃ លែងមានអារម្មណ៍ថាកំសត់ចិត្ត ឯកោទៀតហើយ ពីព្រោះពួកគេសុទ្ធតែបង្ហាញបទពិសោធន៍ជីវិតពិតដែលបានឆ្លងកាត់ពីសេចក្តីស្លាប់ និងរកឃើញជីវិតពិតមានតម្លៃសំរាប់ គ្រួសារ និងសង្គមដែរ។

(មានមិត្តភក្តិធ្លាប់ផឹកជាមួយគ្នា ពេលខ្ញុំប្រាប់គេថា “*ខ្ញុំឈប់ផឹកហើយ សូម្បីតែមួយកំប៉ុង* ”។ គេបន្តនិយាយមកខ្ញុំថា “*ធ្វើអីចឹងបានអ្វីមកវិញ*”។ ខ្ញុំនឹងនិយាយទៅគេវិញថា”*ផឹកអីចឹងបានអ្វីមកវិញ*”។)